00599817

E188/12

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល**
**ពត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: 001/18-07-2007-អវតក អជជស

ភាគីអ្នកដាក់: សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម 2)

ដាក់ជូន អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម អង់គ្លេស និងខ្មែរ (បកប្រែ)

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០

ចំណាត់ថ្នាក់

ចំណាត់ថ្នាក់ឯកសារស្នើដោយភាគីស្នើសុំ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារស្នើដោយអង្គជំនុំជម្រះ:

ចំណាត់ថ្នាក់ឯកសារស្នើ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្ន

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 06 / 09 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

# សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២) និងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម

ដាក់ជូនដោយ:

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

លោក យ៉ុង ផានិត

Ms. Silke STUDZINSKY

បញ្ជូនទៅ :

អង្គជំនុំជម្រះសាលាដំបូង

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

បញ្ជូនទៅ :

អង្គជំនុំជម្រះតុលាការកំពូល

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម សោម សិរីវុទ្ធ

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម យ៉ា ណារិន

ចៅក្រម Motoo NOGUCHI

ចៅក្រម Agniezska KLONOWIECKA-MILART

ចៅក្រម Chandra Nihal JAYASINGHE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខ ០០១ /១៨ ០៧ ២០០៧ អវតក អជសង

E188/12

ចៅក្រម JEAN-Marc LAVERGNE

ចៅក្រម ធូ មុន្នី

ជនជាប់ចោទ

កាំង ហ្គេចអ៊ាវ ហៅ ឌុច

**សហមេធាវីការពារក្តី**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក គង់ ពិសី

លោក ហុង គីមសួន

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី. Martine JACQUIN

លោក. Philippe CANONNE

លោកស្រី. Elizabeth RABESANDRATANA

លោកស្រី. Annie DELAHAIE

លោក. Pierre-Olivier SUR

លោកស្រី. ទីស្រ៊ីនណា

លោក. Karim KHAN

លោក. Alain WERNER

លោកស្រី. Brianne McGONIGLE

លោកស្រី. Fabienne TRUSSES-NAPRUS

លោកស្រី. Christine MARTINEAU

## I. សេចក្តីជូនដំណឹងពីបណ្តឹងសារទុក្ខ

1. សហមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ សូមជូនដំណឹង បណ្តឹងសារទុក្ខ ស្របតាមវិធានផ្ទៃក្នុង ១០៥ (៣) វិសោធនកម្មលើកទី ៣ ។

2. បណ្តឹងសារទុក្ខ ត្រូវបានដាក់ក្នុងនាម លោក ជុំ ស៊ីវ៉ាត់ និងកំណត់ត្រឹមតែ ការខកខានក្នុងការបញ្ចូលឈ្មោះ ប្អូនស្រីថ្លៃរបស់គាត់ ឈ្មោះ គីម សុវណ្ណារី និង កូនរបស់ គីម សុវណ្ណារី នេះ (មិនស្គាល់ ឈ្មោះ)ក្នុង សាលក្រម.[1] ។ ការខកខាននេះ បង្ហាញថា មានកំហុសកើតឡើង ។

## II. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

3. នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១០ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំ [2] ទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីកែប្រែសាលក្រម និងបន្ថែមទំព័រ ២៣០ នៃសាលក្រមជាភាសាអង់គ្លេស និង (ជាភាសាខ្មែរ និងភាសាបារាំងអោយបានស្របគ្នា) នូវឈ្មោះលោកស្រី គីម សុវណ្ណារី និងកូនរបស់គាត់ ។

4. ដោយសារថា អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេច លើការស្នើសុំនេះ តាមរយៈនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើបណ្តឹងឧទ្ធរណ៍លើសាលក្រមនេះ ។

5. សេចក្តីអនុញ្ញាតិជាលាយលក្ខអក្សរសម្រាប់ឧទ្ធរណ៍នេះ ត្រូវមានភ្ជាប់ជាមួយនឹង បណ្តឹងនេះ។

## III. ច្បាប់ពាក់ព័ន្ធ

---

[1] យោងតាមសាលក្រម លោក ជុំ ស៊ីវ៉ាត់ បានបាត់បង់បងប្អូនប្រុសរបស់គាត់ ជុំ ណារិទ្ធ និង ជុំ ស៊ីណារ៉េត (សាលក្រមចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ E188 កថាខណ្ឌ 650) ។

[2] សំណើសុំកែប្រែទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ E188/1.

6. វិធានផ្ទៃក្នុង និងច្បាប់ពាក់ពន្ធ័នឹងបណ្តឹងឧទ្ធរណ៍នេះ យោងតាមមាត្រានៃវិធានផ្ទៃក្នុង ២១, ២៣, ១០៤, ១០៦, និង ១០៧ ។

## IV. គំរូនៃបណ្តឹងសារទុក្ខ

7. យោងតាមវិធានផ្ទៃក្នុង ១០៤ (1) ក និង ខ គម្រូនៃបណ្តឹងសារទុក្ខទៅ អង្គជំនុំជម្រះតុលាការកំពូល (អតក) ពាក់ពន្ធ័នឹងការពិនិត្យមើលលើបណ្តឹងសារទុក្ខប្រឆាំងសាលក្រម ឬ សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងធ្វើឡើង ទាំង (ក) ការភន្តច្រលំ ផ្នែកច្បាប់ ដែលនាំអោយមោឃភាពសាលក្រម និង (ខ) ការភន្តច្រលំផ្នែកអង្គហេតុ ដែលនាំអោយមានភាពអយុត្តិធម៌។

8. ថ្ងៃផុតកំណត់ដាក់បណ្តឹងសារទុក្ខនេះស្របតាមវិធាន ១០៥ (៣) និង ១០៧ (៤) ។

## V. ភាពអាចទទួលយកបាននៃបណ្តឹងសារទុក្ខ

9. យោងតាមវិធានផ្ទៃក្នុង ១០៥ (១) (គ) បណ្តឹងសារទុក្ខ អាចទទួលយកបានសម្រាប់ ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងគោលបំណងនៃផលប្រយោជន៍រដ្ឋប្បវេណីផ្សេងទៀត ប៉ុន្តែក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្តឹងសារទុក្ខប៉ុណ្ណោះ ។ [3] សហព្រះរាជអាជ្ញា បានដាក់សេចក្តីជូនដំណឹង ពីការប្តឹងសារទុក្ខប្រឆាំងនឹងសាលក្រម ។ [4]

---

[3] សេចក្តីបញ្ជាក់បន្ថែម

[4] សេចក្តីជូនដំណឹងពីបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីកាំង ហ្កេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០

10. ហេតុដូច្នេះ បណ្តឹងសារទុក្ខក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន ។

## VI. មូលដ្ឋាននៃបណ្តឹងសារទុក្ខ

ការខកខានក្នុងការដាក់ឈ្មោះរបស់ប្អូនថ្លៃស្រី លោក ជុំ ស៊ីរ៉ាត់ គឺផ្អែកលើមូលដ្ឋាន
នៃការភន្ត័ច្រលំអង្គហេតុ មិនអាចផ្តល់បាននូវយុត្តិធម៌ និង
ការភន្ត័ច្រលំច្បាប់/វិធានផ្ទៃក្នុង ដោយរំលោភលើ វិធាន ២១(១) (ក) និង (គ)
ដែលនាំអោយ សាលក្រមគ្មានសុពលភាព ។

11. យោងតាមប្រពៃណីកម្ពុជា លោកស្រី គីម សុវណ្ណារី បានក្លាយដូចជាប្អូនស្រីរបស់លោក ជុំ ស៊ីរ៉ាត់ តាមរយៈអាពាហ៍ពិពាហ៍ ជាមួយនឹងប្អូនប្រុសរបស់គាត់ លោក ជុំ ណារិទ្ធ ។ ហេតុនេះហើយ លោកស្រី គីម សុវណ្ណារី និងកូនរបស់គាត់ ដែលជាសមាជិកគ្រួសារជិតស្និត គួរត្រូវបានបញ្ចូលក្នុងសាលក្រម ជាសាច់ញាតិរបស់ លោក ជុំ ស៊ីរ៉ាត់ ដែលគាត់បានបាត់បង់ នៅពេលដែលលោក ស៊ីរ៉ាត់ បានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ហើយ ។ ក្នុងបរិបទនៃជនជាតិខ្មែរ នេះ គឺជាករណីដែលសាច់ថ្លៃក្លាយជាសមាជិកគ្រួសារជិតស្និតតាមរយៈ អាពាហ៍ពិពាហ៍ ។

12. ស្របគ្នានេះ ក្នុងសាលក្រម បង្ហាញផងដែរនូវ សាច់ថ្លៃនៃដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ។ [5] ការមិនមានរៀបរាប់ឈ្មោះ លោកស្រី គីម សុវណ្ណារី គឺជាកំណត់ដែលមិនមានសមភាព ដោយអយុត្តិធម៌ ដែលរំលោភលើវិធាន ២១(១) (ក) និង (គ) ។

13. សាលក្រម ដែលរៀបរាប់ពីបញ្ជី នៃសមាជិកគ្រួសារនៃដើមបណ្តឹងរដ្ឋប្បវេណី ក្នុងគោល

---

[5] Ibid., para. 650.

បំណងនៃការផ្តល់ពត៌មាន ។ [6] យ៉ាងហោចណាស់ផ្អែកលើមូលដ្ឋាននេះ លោកស្រី គីម សុវណ្ណារី និងកូនរបស់គាត់ត្រូវបានបញ្ចូលក្នុងសាលក្រម ។

14. ដោយមិនបានបញ្ចូលឈ្មោះប្អូនថ្លៃស្រីរបស់លោក ជុំ ស៊ីរ៉ាត់ និងក្មួយរបស់គាត់ក្នុងសាល ក្រម ទោះបីជាដោយសារកំហុសក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានភ័ន្តច្រលំ លើអង្គហេតុ ។

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើដោយក្តីគោរព:**

- **ប្រកាសបណ្តឹងសារទុក្ខ អាចទទួលយកបាន**
- **កែសាលក្រម និងបញ្ចូលឈ្មោះ លោកស្រី គីម សុវណ្ណារី និង កូនស្រីរបស់គាត់ ក្នុងសាលក្រម**

លោក យុង ផានិត | Ms. Silke STUDZINSKY

ចុះហត្ថលេខានៅ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០

[6] Ibid., footnote 1123.